កំណត់ចំណាំពត៌មាន និងបែបបទនៃការព្រមព្រៀងសម្រាប់កម្រងសំណួរទី១

សួស្តី! ខ្ញុំឈ្មោះ **អេវ ប៊ុយរ៉ូ Eve Bureau** ។ ខ្ញុំធ្វើការនៅ (ផ្នែកសម្ភពមន្ទីរពេទ្យកាល់ម៉ែត និង សាកលវិទ្យាល័យនីស)។ ខ្ញុំចូលរួមក្នុងការស្ទង់មតិថ្នាក់អន្តរជាតិស្តីពីការបំបៅដោះ។ រាល់ពត៌មានដែលពួកយើងប្រមូលមកបាន គឺមានសារប្រយោជន៍ណាស់ចំពោះផ្នែកសេវាសុខភាពនៅក្នុងប្រទេសរបស់អ្នក។ បន្ទាប់ពីបានធ្វើការពិភាក្សាជាមួយនឹងបុគ្គលិកផ្នែកថែទាំ ពួកយើងគិតថាអ្នកអាចចូលរួមជួយពួកយើង តាមរយៈការឆ្លើយសំណួរមួយចំនួនដែលពាក់ព័ន្ធនឹងការបំបៅដោះ (ឬការខកខានមិនបានបំបៅ) ដល់កូនរបស់អ្នក។ បើតាមទស្តាប់ សំណួរទាំងនេះត្រូវចំណាយពេល៤៥នាទីច្រើនបំផុត។ រាល់ពត៌មានទាំងឡាយដែលយើងខ្ញុំនឹងទទួលបានពីអ្នក គឺត្រូវបានលាក់ទុកយ៉ាងត្រឹមត្រូវ ហើយពត៌មានទាំងនេះមិនត្រូវបានផ្តល់អោយទៅអ្នកផ្សេង ក្រៅអំពីក្រុមសមាជិកធ្វើការស្ទង់មតិឡើយ។ អ្នកមិនត្រូវបានបង្ខំអោយចូលរួមនៅក្នុងការស្ទង់មតិនេះទេ ប៉ុន្តែខ្ញុំសង្ឃឹមថាអ្នកនឹងយល់ព្រមធ្វើព្រោះថាការបញ្ចេញមតិរបស់អ្នកមានសារៈសំខាន់ខ្លាំងណាស់។
វាគ្មានចម្លើយ**ត្រូវ** ឬ **ខុស** សម្រាប់សំណួរទាំងអស់នោះឡើយ។ ប្រសិនបើមានសំណួរណាមួយដែលខ្ញុំសួរទៅ ហើយអ្នកមិនចង់ឆ្លើយ សូមប្រាប់ខ្ញុំ ខ្ញុំនឹងរំលងសំណួរនេះរួចបន្តទៅសំណួរបន្ទាប់ទៀត។ អ្នកអាចនិយាយកាត់បទសម្ភាសន៍នេះបានគ្រប់ពេលទាំងអស់។ ប្រសិនបើអ្នកចង់បានពត៌មានច្រើនបន្ថែមទៀតស្តីពីការស្ទង់មតិនេះ អ្នកអាចទាក់ទងទៅអ្នកដែលមានរាយនាមនៅក្នុងតារាងដែលខ្ញុំនឹងទុកឲ្យអ្នក នៅពេលបទសម្ភាសន៍របស់ពួកយើងចប់សព្វគ្រប់។

តើអ្នកយល់ព្រមឆ្លើយសំណួរទាំងអស់របស់ខ្ញុំទេ : យល់ព្រម/មិនយល់ព្រមទេ
តើអ្នកមានសំណួរ ដែលត្រូវសួរមកខ្ញុំវិញទេ ?
បន្ទាប់មក តើខ្ញុំអាចចាប់ផ្តើមធ្វើបទសម្ភាសន៍ឥឡូវនេះបានទេ?

ហត្ថលេខាអ្នកស្ទង់មតិ:
ខែ/ឆ្នាំដែលស្ទង់មតិ (ខែ/ឆ្នាំ សូមកុំកត់ត្រាថ្ងៃចូល) : |_|_|_|_|_|_|_|_|